គម្រូនៃពាក្យបណ្ដឹង (សំណុំរឿង 2 )

# ពាក្យបណ្ដឹង

(ការសរសេរអំពីភាគីនៃបណ្ដឹងជាដើម ៖ សង្ខេប)

ទី១ ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ

១.បង្គាប់ឲ្យចុងចម្លើយ Y ចុះចេញពីដី និង ផ្ទះ (L) ហើយប្រគល់ឲ្យទៅដើមចោទ X។

២.បង្គាប់ឲ្យចុងចម្លើយ Y បង់ប្រាក់ចំនួន២០០០ដុល្លារ និង បង់ការប្រាក់នៃខែនេះ ចំនួន៥% ក្នុង១ឆ្នាំគិតចាប់ពីថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៧ រហូតដល់ថ្ងៃសងរួច។

៣.បង្គាប់ឲ្យចុងចម្លើយ Y បង់ប្រាក់ចំនួន២០០០ដុល្លារក្នុង១ខែ ឲ្យទៅដើមចោទ X គិតចាប់ពីថ្ងៃទី២ ខែតុលា ឆ្នាំ២០១៧ រហូតដល់ពេលដែលចុងចម្លើយបានចុះចេញ ហើយប្រគល់ដី និង ផ្ទះ (L)។

៤. ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ Y។

និងទាមទារឲ្យតុលាការចេញសាលក្រម និង ប្រកាសឲ្យអនុវត្តជាបណ្ដោះអាសន្ន។

ទី២ មូលហេតុនៃការទាមទារ

១.នៅថ្ងៃទី១ ខែមីនា ឆ្នាំ២០១៧ ដើមចោទ X បានចុះភតិសន្យាអំពីដី និង ផ្ទះ (L) ដែលមានខ្លឹមសារដូចខាងក្រោម ៖ (ស.១ ៖ លិខិតភតិសន្យា)

ភតិបតី ៖ X

ភតិកៈ ៖ Y

វត្ថុជួល ៖ ដី និង ផ្ទះ (L)

ថ្លៃឈ្នួល ៖ ២០០០ដុល្លារ/ខែ

កាលបរិច្ឆេទនៃការបង់ថ្លៃឈ្នួល ៖ ត្រូវបង់នៅថ្ងៃទី១ជារៀងរាល់ខែ

អំឡុងពេលនៃភតិសន្យា ៖ ពីថ្ងៃទី១ ខែមីនា ឆ្នាំ២០១៧ រហូតដល់ថ្ងៃចុងក្រោយខែកុម្ភៈ ឆ្នាំ២០១៩

ខសន្យាពិសេស ៖ ក្នុងករណីដែលភតិកៈមិនបានបង់ថ្លៃឈ្នួលចំនួន២ខែ កិច្ចសន្យានៃរឿងក្ដីនេះនឹងត្រូវរំលាយដោយស្វ័យប្រវត្តិ។

២. នៅថ្ងៃដដែល ដើមចោទបានប្រគល់ដី និង ផ្ទះ (L) ឲ្យទៅចុងចម្លើយ ផ្អែកតាមភតិសន្យានៃរឿងក្ដីនេះ។

៣.ចាប់ពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៧ ចុងចម្លើយមិនដែលបានបង់ថ្លៃឈ្នួលឲ្យទៅដើមចោទទាល់តែសោះ ហើយនៅមិនទាន់បានបង់ចំនួន២ខែឡើងទៅ។

៤.ដូច្នេះ ដើមចោទទាមទារឲ្យចុងចម្លើយបង់ថ្លៃឈ្នួលក្នុងខែកញ្ញា និង ប្រាក់សំណងនៃការខូចខាតដោយសារការយឺតយ៉ាវដោយផ្អែកលើសិទ្ធិទាមទារថ្លៃឈ្នួលយោងតាមភតិសន្យានៃរឿងក្ដីនេះ ព្រមទាំង

បង់ប្រាក់សំណងនៃការខូចខាតដោយសារការយឺតយ៉ាវចំនួន២០០០ដុល្លារក្នុង១ខែ គិតចាប់ពីថ្ងៃ២ ខែតុលា ឆ្នាំ២០១៧ ដែលជាថ្ងៃបន្ទាប់ពីថ្ងៃត្រូវប្រគល់កម្មវត្ថុនៃភតិសន្យាក្នុងរឿងក្តីនេះ និង ក៏ជាបន្ទាប់នៃការបញ្ចប់ភតិសន្យា រហូតដល់ថ្ងៃដែលភតិកៈត្រូវបានចុះចេញនិងប្រគល់រួច។

ភស្តុតាង

១.ភស្តុតាង លេខ ស.១ លិខិតភតិសន្យា

ឯកសារភ្ជាប់មកជាមួយ

១.ច្បាប់ចម្លងដើមនៃពាក្យបណ្តឹង ១ច្បាប់
២.ភស្តុតាង លេខ ស.១ (ច្បាប់ចម្លង) ១ច្បាប់
៣.កិច្ចសន្យាអាណត្តិក្នុងការធ្វើបណ្តឹង ១ច្បាប់

# ឯកសារចម្លើយ

(ការសរសេរអំពីភាគីនៃបណ្ដឹងជាដើម ៖ សង្ខេប)

ទី១ ការឆ្លើយតបចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ
១.ច្រានចោលការទាមទារគ្រប់ចំណុចរបស់ដើមចោទ X ។
២.ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមចោទ X ។

ទី២ ការទទួលស្គាល់ ឬ មិនទទួលស្គាល់ចំពោះមូលហេតុនៃការទាមទារ
១.ទទួលស្គាល់ទាំងស្រុងនូវមូលហេតុនៃការទាមទារ ១។
២.ទទួលស្គាល់ទាំងស្រុងនូវមូលហេតុនៃការទាមទារ ២។
៣.ទទួលស្គាល់ទាំងស្រុងនូវមូលហេតុនៃការទាមទារ ៣។
៤.មានវិវាទចំពោះមូលហេតុនៃការទាមទារ ៤។

ទី៣ ការតវ៉ា-ការមិនអនុវត្តករណីយកិច្ចជួសជុលរបស់ភតិបតី

ផ្ទះជួលនៃរឿងក្ដីនេះជ្រាបទឹកខ្លាំង (ង.១ ៖ រូបថត) ហើយចាប់តាំងពីថ្ងៃទី១ ខែសីហា ឆ្នាំ២០១៧មក ចុងចម្លើយបានទាមទារទៅកាន់ដើមចោទឲ្យជួសជុលផ្ទះនេះជាច្រើនដងផងដែរ (ង.២ ៖ លិខិតជូនដំណឹង)។

ប៉ុន្តែ ដើមចោទមិនបានអើពើនឹងការជួសជុលផ្ទះជួលនៃរឿងក្ដីនេះ ហើយមិនបានឆ្លើយតបអ្វីទេ។

ដូច្នេះហើយ ចុងចម្លើយមិនអាចប្រើប្រាស់ផ្ទះជួលនៃរឿងក្ដីនេះបានឡើយ។

ភតិបតី មានករណីយកិច្ចធ្វើឲ្យស្ថានភាពនៃកម្មវត្ថុភតិសន្យាសមស្របទៅតាមគោលបំណងនៃភតិសន្យា ដើម្បីឲ្យភតិកៈអាចប្រើប្រាស់ និង អាស្រ័យផលបាន។ ហើយ ជាការតបទៅនឹងការអនុវត្តករណីយកិច្ចរបស់ភតិបតី ករណីយកិច្ចត្រូវបង់ថ្លៃឈ្នួលរបស់ភតិកៈនឹងត្រូវកើតឡើង។ ដូច្នេះហើយ គេគិតថា ភតិកៈក៏អាចបដិសេធចំពោះការមិនអនុវត្តកាតព្វកិច្ចបង់ថ្លៃឈ្នួលផងដែរ រហូតដល់ពេលដែលភតិបតីបានធ្វើឲ្យស្ថានភាពនៃកម្មវត្ថុភតិសន្យាសមស្របទៅនឹងការប្រើប្រាស់ និង អាស្រ័យផល ហើយនេះក៏ជាការត្រឹមត្រូវទៅនឹងគោលការណ៍សមភាពផងដែរ។

ហេតុនេះហើយ ចុងចម្លើយមិនចាំបាច់បង់ថ្លៃឈ្នួលទេ រហូតទាល់តែដើមចោទបានជួសជុលផ្ទះជួលនៃរឿងក្ដីនេះ ហើយទោះបីជាបានបដិសេធមិនបង់ថ្លៃឈ្នួលក៏ដោយ ក៏ការទទួលខុសត្រូវចំពោះការអនុវត្តយឺតយ៉ាវមិនកើតមានដែរ។

ទី៤ សរុប

ផ្អែកតាមការរៀបរាប់ខាងលើ ដូច្នេះ ការទាមទាររបស់ដើមចោទពុំមានមូលហេតុឡើយ។

ភស្តុតាង

១.ភស្តុតាង លេខ ង.១ រូបថត

២.ភស្តុតាង លេខ ង.២ លិខិតជូនដំណឹង

ឯកសារភ្ជាប់មកជាមួយ

១.ភស្តុតាងលេខ ង.១ និង ង.២ (ច្បាប់ចម្លង) ១ច្បាប់

២.កិច្ចសន្យាអាណត្តិក្នុងការធ្វើបណ្តឹង ១ច្បាប់

គម្រូនៃឯកសារត្រៀម (សំណុំរឿង 2 )

# ឯកសារត្រៀមលើកទី១

(ការសរសេរអំពីភាគីនៃបណ្តឹងជាដើម ៖ សង្ខេប)

ទី១ អំពីការតវ៉ាចំពោះការផ្តួយទៅនឹងករណីយកិច្ចជួសជុលរបស់ភតិបតី

ដោយសារតែចុងចម្លើយបានទាក់ទងមកថា ផ្ទះបានជ្រាបទឹក ដូច្នេះ នៅថ្ងៃទី២០ ខែសីហា ឆ្នាំ ២០១៧ ដើមចោទបានទៅដល់ផ្ទះជួលនៃរឿងក្តីនេះ ដើម្បីបញ្ជាក់ឲ្យច្បាស់ថា មាន ឬ គ្មានការជ្រាបទឹក ។

ប៉ុន្តែ នៅថ្ងៃនោះ ដើមចោទបានធ្វើការបញ្ជាក់អំពីការជ្រាបទឹក ប៉ុន្តែ មិនឃើញមានជ្រាបកន្លែងណាឡើយ ទោះបីជាមេឃភ្លៀងខ្លាំងយ៉ាងណាក៏ដោយ (ស.២ ៖ លិខិតរាយការណ៍ស្តីអំពីការអង្កេត)។

ហេតុដូច្នេះហើយ ផ្ទះជួលក្នុងរឿងក្តីនេះមិនមានការជ្រាបទឹកឡើយ ហើយដើមចោទក៏មិនមានករណីយកិច្ចជួសជុលរបស់ភតិបតីឡើយ។

ទី២ សរុប

ដូច្នេះ ហើយតុលាការគួរតែទទួលស្គាល់ការទាមទារគ្រប់ចំណុចរបស់ដើមចោទ។

សូមអរគុណ